# ការសំម្ភាសន៍របស់លោកយាយ អ៊ុយ ភាព

កះ អ្នកដែលសំម្ភាសន៍គេ រត្ន ស្រីភាព ខះ អ្នកដែលត្រូវគេសម្ភាសន៍ អ៊ុយ ភាព

**<u>ការសមម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់លោកយាយឈ្មោះ អ៊ុយ ភាព</u>**

លោកយាយជាមនុស្សដែលមានការតស៊ូខិតខំប្រឹងប្រែងរកស៊ីគាត់ចិត្តល្អមិនដែលឈ្លូស ជាមួយអ្នកជិតខាងណាទេគាត់ចិត្តល្អចេះជួយគ្នាទៅវិញទៅមក។

កះ ជាដំបូងខ្ញុំសូមជំរាបសួរលោកយាយខ្ញុំបាទឈ្មោះ រត្ន ស្រីភាព ខ្ញុំសូមអនុញ្ញាតលោកយាយធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់លោកយាយហើយខ្ញុំធ្វើឡើង ដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថា BYU ដែលមានទីតាំងនៅសាហាករដ្ធអាមេរិចដើម្បីរក្សាជីវប្រវត្តិរបស់លោកយាយទុកអោយកូន ចៅជំនាន់ក្រោយលោកយាយគាត់បានដឹងបានស្តាប់ហើយដើម្បីអោយគាត់បានដឹងថាអ្នក ជំនាន់មុនមានការលមបាកអ្វីខ្លះនឹងបានជួបឧបសគ្គអ្វីខ្លះ។

កះ ចា៎ចឹងតើលោកយាយមានឈ្មោះអ្វីដែលលោកយាយ?

ខះ ខ្ញុំមានឈ្មោះថា ភាព។

កះ ចា៎ចឹងឈ្មោះពេញរបស់លោកយាយភាពនឹងមានឈ្មោះអ្វីដែលលោកយាយ?

ខះ ឈ្មោះពេញខ្ញុំមានឈ្មោះថា អ៊ុយ ភាព។

កះ ចា៎ហើយចឹងតើលោកយាយមានឈ្មោះគេហៅខាងក្រៅទេ?

ខះ ខ្ញុំអត់មានទេ។

កះ ចា៎ចឹងតើសព្វថ្ងៃនឹងតើលោកយាយមានអាយុប៉ុន្មានឆ្នាំហើយ?

ខះ ខ្ញុំមានអាយុ៦៧ឆ្នាំបើលចូលឆ្នាំនឹងខ្ញុំអាយុ៦៨ឆ្នាំហើយ។

កះ
ចា៎លោកយាយចូល៦៨ឆ្នាំហើយចឹងតើលោកយាយកើតនៅឆ្នាំណាខែណាដែលលោកយាយ?

ខ៖ ខ្ញុំមិនដឹងថាកើតឆ្នាំណាទេមីនាងខ្ញុំអត់ដឹងទេ។

ក៖ ចាំចឹងបើឆ្នាំខ្មែរវិញដូចជា ជូត ឆ្លូវ ខាល ថោះវិញតើលោកយាយកើតឆ្នាំណាដែលលោកយាយ?

ខ៖ ខ្ញុំអត់ដែលដឹងទេ។

ក៖ ចាំមិនអីទេលោកយាយចាំចឹងលោកយាយអត់ដែលដឹងទេលោកយាយ?

ខ៖ ចាំខ្ញុំមិនដែលដឹងផងនឹង។

ក៖ ចាំចឹងតើលោកយាយអាចប្រាប់ខ្ញុំបានទេថាលោកយាយកើតនៅស្រុកណាដែលលោកយាយ?

ខ៖ ស្រុកកំណើតខ្ញុំនៅឯងកាហែងកាខ្វាង។

ក៖ ចាំនៅកាហែងនៅខេត្តកំពង់ស្ពឺនឹងដែលលោកយាយ?

ខ៖ ចាំ!

ក៖ ចាំតែនៅខាងលិច?

ខ៖ ចាំខាងលិតជ្រាយស្ពឺ។

ក៖ ចាំចឹងលោកយាយផ្លាស់មកនៅនឹងប៉ុន្មានឆ្នាំហើយលោកយាយ?

ខ៖ មកនៅនឹងតាំងពីជំនាន់អាពត។

ក៖ ចាំនៅក្នុងភូមិ ដក់ពរនឹងឃុំវល័សរកំពុងស្ពឺនឹងយូរមកហើយលោកយាយ?

ខ៖ ចាំ!

ក៖ ចឹងលោកយាយបានមករស់នៅតាំងពីអាពតមកម្លះលោកយាយចឹងលោកយាយមានបងប្អូនបង្កើតនឹ

ងប៉ុន្មនាមាក់ដែលលោកយាយ?

ខៈបងប្អូនបង្កើតខ្ញុំនឹងមានទាំងអស់នឹង៩នាក់តែខ្ញុំកាលនឹងបានបែកគ្នានឹងអស់ហើយមិនបានរស់នៅជាមួយនឹងគ្នាទេ។

កៈចឹងបងប្អូនលោកយាយមានដល់ទៅ៩មាក់ចឹងលោកយាយហើយតើមានបងប្អូនប្រុសនឹងប៉ុន្មាននាក់ហើយនឹងស្រីនឹងប៉ុន្មាននាក់ដែលលោកយាយ?

ខៈបងប្អូនខ្ញុំនឹងមានប្រុសនឹង៨នាក់ប្អូនខ្ញុំនឹងប្រុស២នាក់ហើយបងប្អូនខ្ញុំនឹងមានតែស្រីនឹងតែ២នាក់នឹងទេ។

កៈអូចឹងបងប្អូនរបស់លោកយាយមានដល់ទៅ៩នាក់នឹងហើយចឹងមានស្រីនឹងតែ២នាក់នឹងទេសល់ប៉ុន្មនានឹងប្រុសទាំងអសចឹងលោកយាយហើយចឹងលោកយាយជាកូនទីប៉ុន្មានដែលលោកយាយ?

ខៈខ្ញុំនឹងជាកូនទី២។

កៈចឹងលោកយាយជាកូនទី២ចឹងកាលនឹងលោកយាយជាកូនពៅហើយលោកយាយ?

ខៈអត់ទេខ្ញុំនឹងជាកូនទី២បងន្ទុបពីបងខ្ញុំនឹង។

កៈចឹងលោកយាយជាកូនទី២វិញចឹងលោកយាយហើយលោកយាយអាចប្រាប់ខ្ញុំបានទេថាលោកយាយមានបងប្អូនលោកយាយនឹងមានដល់៩នាក់ចឹងតើលោកយាយអាចចាំឈ្មោះពួកគាត់ទេលោកយាយ?

ខៈខ្ញុំនៅចាំតើបងប្អូនខ្ញុំនឹង។

កៈចឹងលោកយាយអាចប្រាប់ឈ្មោះបងប្អូនលោកយាយបានទេថាគាត់នឹងមានឈ្មោះអីដែលលោកយាយ?

ខៈបងខ្ញុំទី១នឹងឈ្មោះភីបន្តមកទៀតនឹងខ្ញុំឈ្មោះភាពហើយបន្តមកទៀតនឹងផក់ហើយបន្តមកទៀតនឹងឈ្មោះម៉ាច។

កៈ៦ហើយលោកយាយចឹងប្អូនលោកយាយនឹងមានឈ្មោះអីទៀតដែលលោកយាយនៅសល់៧ហើយនឹង៨ /៩នឹងលោកយាយ?

ខៈបន្តមកទៀតនឹងឈ្មោះសុខាបន្តមកទៀតនឹងឈ្មោះសុខឹម។

កៈចឹងលោកយាយនឹងមានឈ្មោះថាសុភាពចឹងលោកយាយហើយលោកយាយបានចាំសាច់រឿងលោកយាយដែលកាលនឹងលោកយាយបាននៅពីតូចៗមកចឹងលោកយាយដែលបានចាំទេ?

ខៈមានបានចាំសាច់រឿងអីទេខ្ញុំនឹងនាងហើយកាលនឹងខ្ញុំនឹងបានសាច់រឿងតែនៅក្រនឹងខ្ញុំនឹង។

កៈចឹងលោកយាយអាចប្រាប់ខ្ញុំបានទេថាកាលនឹងលោកយាយបានចាំសាច់រឿងកាលនឹងដែលលោកយាយនឹងបានពិបាកខ្លះចឹងលោកយាយអាចប្រាប់ចៅបានទេលោកយាយ?

កៈកាលនឹងខ្ញុំនឹងបានអាណិតឪពុកខ្ញុំនឹងណាស់កាលនឹងគាត់បានធ្វើជាទាហាមហើយកាលនឹងឪពុកខ្ញុំនឹងគាត់បានងងឹតភ្នែកចឹងកាលនឹងតែគាត់នឹងនៅតែបានខំធ្វើជាទាហានទៀតកាលនឹងគាត់នបានធ្វើជាទាហានជំនាន់អីសៈកាលនឹងហើយគាត់នឹងបានបានធ្វើកាលអោយគេនឹងមិនបានកើតទេកាលនឹងដោយសារតែភ្នែកគាត់បានងងឹមចឹងកាលនឹងហើយម៉ែខ្ញុំនឹងបានទៅបើលុយនឹងបានពីបារាំងនឹងបានមកដាក់ហើយចឹងកាលនឹងម៉ែខ្ញុំនឹងបានយកលយុនឹងបានមកទិញដីហើយនឹងបាមធ្វើផ្ទះបានតែ១ខ្នងនឹងទេកាលនឹងហើយខ្ញុំនឹងបងប្អូនខ្ញុំនឹងបានមករស់នៅជិតវត្តកាលនឹងដែលមានឈ្មោះថាវត្តរត្ននាចឹងកាលនឹងហើយកាលនឹងខ្ញុំនឹងបងប្អូនខ្ញុំនឹងក្រណាស់កាលនឹងហើយក្រោយមកម៉ែខ្ញុំនឹងគាត់បានឡើងទៅសុំសម្តេចតាកាលនឹងសុំអោយសម្តេចតានឹងជួយគាត់នឹងមានប្រាប់ខែដែលឪពុកខ្ញុំនឹងបានធ្វើជាទាហាននៅជំនាន់អីសៈនឹងហើយក្រោយមកសម្តេចតានឹងទ្រង់បានផ្តលអោយឪពុកខ្ញុំនឹងបានប្រាប់ខែមកវិញចឹងកាលនឹងម៉ែខ្ញុំនឹងបានទៅបើលយុនឹងកាលនឹងគាត់ម៉ែខ្ញុំនឹងគាត់បានទិញតែអង្ករ កាលនឹងតែ១បាវ
នឹងលុយនឹងដែលម៉ែខ្ញុំនឹងគាត់បានបើនឹងមកនឹងកាលនឹងដោយសារតែលុយបរាប់ខែឪពុកខ្ញុំលានឹងបានម៉ែខ្ញុំនឹងគាតព្ញបានបានចិញ្ចឹមកូនគាត់នឹងកាលនឹង។

កៈចឹងលោកយាយអាចប្រាប់ខ្ញុំបានទេថាលោកយាយកាលនឹងមានដែលបានចូលចិត្តធ្វើអីជាមួយនឹងបងប្អូនលោកយាយកាលនឹងលោកយាយ?

ខៈកាលនឹងខ្ញុំមិនបានមានអីកាលនឹងបានធ្វើទេមានតែស្រែតែមួយនឹងកាលនឹង។

កៈចាំចឹងកាលនឹងលោកយាយនឹងជាអ្នកដែលបានធ្វើស្រែជាមួយនឹងបងប្អូនលោកយាយកាលនឹងចាំនឹងហើយដែលបានថាលោកយាយមានកាលចូលចិត្តនឹងបានធ្វើស្រែនឹងជាមួយនឹងគ្នាកាលនឹងលោកយាយ?

ខះចាំមានតែចឹងខ្ញុំនឹង។

កះចាំចឹងលោកយាយដែលបានធ្វើកាលដក់ស្ទូនកាលនឹងលោកយាយធ្វើស្រែនឹងដោយខ្លួនឯងឬមួយកាលនឹងលោកយាយបានធ្វើនឹងអោយគេលោកយាយកាលនឹង?

ខះខ្ញុំកាលនឹងបានធ្វើនឹងដោយខ្លួនឯងនឹងកាលនឹងមិនបានធ្វើអោយគេទេខ្ញុំនឹងហើយកាលនឹងខ្ញុំនឹងបានធ្វើស្រែនឹងតែម្នាក់ឯងនឹងខ្ញុំនឹងកាលនឹងហើយខ្ញុំកាលនឹងបានភ្ជួរហើយខ្ញុំនឹងបានរស។

កះចឹងកាលនឹងលោកយាយនឹងបាធ្វើនឹងជាមួយនឹងបងប្អូនលោកយាយទៅកាលនឹង?

ខះខ្ញុំនឹងបានធ្វើស្រែនឹងតែម្នាក់ឯងនឹងកាលនឹងដែលខ្ញុំនឹងបានធ្វើនឹងដក់ហើយនឹងស្ទូនតែឯង។

កះចុះបងប្អូនរបស់លោកយាយកាលនឹងគាត់នឹងមិនបានមានអ្នកណានឹងបានជួយទេលោកយាយ?

ខះកាលនឹងប្អូនខ្ញុំនឹងវាកាលនឹងបាននៅពីតូចចឹងកាលនឹងហើយបងៗខ្ញុំនឹងគេកាលនឹងបានទៅរៀនកាលនឹងចឹងទៅកាលនឹងបងខ្ញុំនឹងបានចូលធ្វើទាហាននឹងកាលនឹងដែលគាត់នឹងបានចូលមកជំនួលឪពុកខ្ញុំនឹងដែលគាត់នឹងបាននៅជំនាន់អីសៈកាលនឹងដែលបងខ្ញុំនឹងបានធ្វើនឹងកាលនឹងបងខ្ញុំនឹងគាត់នឹងបានទៅរៀនកាលនឹងបាននៅអង្គរអនទ្រុបកាលនឹងពីកំពុងចាមគេបានយកតាំងពីតូចមកចឹងប្រហែលកាលនឹងក្មេងជំទង់កាលនឹងយកទៅកាលនឹងបានធ្វើជាកូនសិស្សកាលនឹងហើយកាលនឹងគេបានហៅថាអង្គសទ្រុកហើយកាលនឹងបងខ្ញុំនឹងត្រូវបានគេនឹងយកទៅជំនួតឪពុកខ្ញុំកាលនឹងដែលបងខ្ញុំនឹងគាត់នឹងបានទៅកាលនឹងហើយគេនឹងបានអោយបងខ្ញុំនឹងបានទៅរៀននៅកំពុងចាមកាលនឹងហើយបងខ្ញុំនឹងគាត់នឹងបានដើរចេញពីកំពុងចាមនឹងហើយបានមករៀននៅពេញទៀតកាលនឹងហើយកាលនឹងបងខ្ញុំនឹងបានដល់ជំនាន់១៨មិថុនាកាលនឹងគេនឹងបានចេរបងខ្ញុំកាលនឹងហើយកាលនឹងបងខ្ញុំនឹងបានធ្វើជាទាហានផងហើយនឹងកូនសិស្សផងកាលនឹងហើយដល់ពេលដល់ជំនាន់១៨មិថុនានឹងកាលនឹងគេនឹងបានទៅខ្ចីទាហានកាលនឹងយកទៅវ៉ៃនៅជំនាន់លុននលនឹងកាលនឹងចឹងតាំងពីពេលនឹងមកបងប្អូនខ្ញុំនឹងបានបែកគ្នាកាលនឹងហើយដល់មកជំនាន់អាពទទៀតនឹងកាលនឹងខ្ញុំនឹងបានបានងាប់បងខ្ញុំហើយកាលនឹងខ្ញុំនឹងបានបែកម៉ែខ្ញុំហើយនឹងឪពុកកាលនឹងហើយបងប្អូនខ្ញុំនឹងទាំងអស់នឹងបានស្លាប់៥ហើយនឹង៦នាក់កាល

នឹងបានស្លាប់នឹងទាំងអស់កាលនឹងនៅសល់តែខ្ញុំនឹងហើយនឹងប្អូនខ្ញុំនឹងប្រុសហើយកាលនឹងអត់ពៅទេកាលនឹងបន្តពីខ្ញុំនឹង។

ក៖ចឹងបងប្អូនលោកយាយនិយាយរួចទៅកាលនឹងនៅពេលដែលបានចប់អាពតមកចឹងកាលនឹងបានស្លាប់អស់ខ្លះហើយតែបាននៅសល់តែលោកយាយហើយនឹងប្អូនលោកយាយដែលគាត់នឹងជាប្អូនប្រុសចឹងលោកយាយហើយបាននៅសល់តែ២នាក់នឹងទេចឹងលោកយាយរាល់ថ្ងៃនឹងលោកយាយនៅសល់តែ២នាក់នឹងហើយគាត់នឹងបានរស់នៅណាដែលលោកយាយកាលនឹង?

ខ៖ប្អូនខ្ញុំនឹងគាត់មឹងបានរស់នៅពពែកភ្នំនឹង។

ក៖ចឹងកាលនឹងប្អូនលោកយាយនឹងគាត់នឹងបានរស់នៅពពែកភ្នំនឹងតែគាត់នឹងបានរស់នៅខេត្តស្ទឹនឹងលោកយាយ?

ខ៖ ចាំ!

ក៖ហើយលោកយាយដែលបានចាំឈ្មោះលោកឪពុកហើយនឹងអ្នកម្ដាយរបស់លោកយាយទេ?

ខ៖ចាំខ្ញុំនឹងបាននៅចាំតើមិនបានភ្លេចទេឪពុកម៉ែខ្ញុំនឹង។

ក៖ហើយសំរាប់លោកឪពុកហើយនឹងអ្នកម្ដាយរបស់លោកយាយតើពួកគាត់នឹងមានឈ្មោះអីដែលលោកយាយ?

ខ៖ឪពុកខ្ញុំនឹងគាត់នឹងមានឈ្មោះថាតាភឿងម៉ែខ្ញុំនឹងគាត់មានឈ្មោះថាផ៉ាន់។

ក៖បើសិនជាអាចតើលោកយាយអាចចាំទេថាលោកឪពុកហើយនឹងអ្នកម្ដាយរបស់លោកយាយតើគាត់នឹងបានកើតនៅឆ្នាំណាខ្លះដែលលោកយាយ?

ខ៖អត់បានដឹងទេនាងកាលនឹងខ្ញុំមិនបានចាប់អារម្មណ៍រឿងនឹងទេកាលនឹងខ្ញុំនឹងខ្ញុំមិនបានដឹងទាំងអស់នឹងតែមន្ត។

ក៖ចឹងកាលនឹងលោកយាយដែលបានដឹងថាកាលដែលលោកយាយបានរស់នៅជាមួយនឹងលោកឪពុកហើយនឹងអ្នកម្ដាយរបស់លោកយាយកាលនឹងតើលោកយាយដែលបានចាំថាពួកគាត់នឹងបានប្រកបមុខរបស់អីដែលលោកយាយកាលនឹង?

ខ៖កាលនឹងឪពុកម្ដាយខ្ញុំនឹងកាលនឹងគាត់បានធ្វើតែស្រែនឹងកាលនឹង។

ក៖ចាំចឹងកាលនឹងអ្នកម្ដាយលោកយាយហើយនឹងលោកឪពុកលោកយាយកាលនឹងគាត់នឹងបានធ្វើតែស្រែនឹងកាលនឹងហើយកាលនឹងគាត់នឹងមិនបានធ្វើជាមន្ត្រីរាជការទេកាលនឹង?

ខ៖អត់ទេគាត់នឹងបានចាស់ហើយកាលនឹងគាត់នឹងបានឈប់ធ្វើហើយកាលនឹងតែគាត់នឹងបានអោយបងខ្ញុំនឹងបានធ្វើម្ដងចឹងទៅកាលនឹងហើយកាលនឹងឪពុកខ្ញុំនឹងគាត់ជាទាហាននឹងដែលបានចាស់ហើយចឹងកាលនឹងគាត់នឹងបានជាគាត់នឹងបានឺប់ចឹងកាលនឹងហើយយ៉ាងទៀតនឹងគាត់នឹងបានងងឹតភ្នែកទៀតកាលនឹងចឹងបានគាត់នឹងបានឺប់ចឹងតែម្ដងទៅ។

ក៖ចឹងកាលនឹងគាត់នឹងបានឈឺចឹងកាលនឹងគេនឹងបានអោយគាត់នឹងបានសុំរាក់ចឹងទៅកាលនឹងលោកយាយហើយយ៉ាងទៀតម៉ែលោកយាយកាលនឹងគាត់បានធ្វើតែស្រែដែលចឹងកាលនឹង?

ខ៖ចាំដូចគ្នាបឹងកាលនឹងម៉ែខ្ញុំហើយនឹងឪពុកខ្ញុំនឹងគាត់ជាអ្នកស្រែកាលនឹង។

ក៖ចាំចឹងលោកយាយបើអាចកាលនឹងតើលោកយាយបានដឹងថាអ្នកម្ដាយរបស់លោកយាយហើយនឹងលោកឪពុករបស់លោកយាយកាលនឹងតើគាតើនឹងជាមនុស្សបែនណាដែលលោកយាយ?

ខ៖ជាមនុស្សបែកណាគាត់កាលនឹងជាអ្នកដែលបានទាន់ត្រង់គាត់កាលនឹងជាអ្នកដែលបានរកស៊ីនឹងតាមធម្មតានឹងកាលនឹងហើយកាលនឹងឪពុកខ្ញុំនឹងគាត់នឹងជាអ្នកដែលបានពិការចឹងកាលនឹងគាត់នឹងមិនបានទៅណានឹងបានរួចទេកាលនឹងហើយគាត់នឹងអត់បានរកអីនឹងបានផងនឹងកាលនឹងហើយកាលនឹងគាត់នឹងបានតែដេកចឹងកាលនឹង។

ក៖អូចាំចឹងកាលនឹងលោកឪពុករបស់លោកយាយកាលនឹងគាត់នឹងរកអីមិនបានទេហើយមានតែអ្នកម្ដាយរបស់លោកយាយទេកាលនឹងដែលបានរកអីមកចិញ្ចឹមបងប្អូនលោកយាយកាលនឹងរាល់បាននៅសល់រាល់ថ្ងៃនឹងចឹងលោកយាយ?

ខ៖ចឹងលោកយាយអាចបានប្រាប់ខ្ញុំទៀតបានទេថាកាលនឹងលោកយាយដែលបានចាំសាច់រឿងអីខ្លះកាលនឹងជាមួយនឹងលោកឪពុកហើយនឹងម្ដាយរបស់លោកយាយកាលនឹងថាកាលនឹងពួកគាត់នឹងបានរស់នៅពីក្មេងចឹងកាលនឹងហើយគាត់នឹងដែលបានប្រាប់លោកយាយទេកាលនឹង?

ខ៖អត់ដែលបាននិយាយអីទេកាលនឹងម៉ែខ្ញុំហើយនឹងឪពុកខ្ញុំដែលកាលនឹងខ្ញុំនឹងតែនៅពេលដេលខ្ញុំនឹងបានរស់នៅជាមួយនឹងម្ដាយខ្ញុំកាលនឹងគាត់នឹងបាននៅក្មេងដែលចឹងកាលនឹងហើយម្ដាយខ្ញុំនឹងកាលនឹងគាត់ម្ដាយខ្ញុំនឹងក៏គាត់នឹងបាននៅក្មេងដេលចឹងកាលនឹងហើយនឹងបានលក់នំបាញ់ចុកចឹងកាលនឹងហើយខ្ញុំនឹងបានទូលនំបាញ់ចុកនឹងដើរលក់តាមផ្ទះគឺចឹងកាលនឹងខ្ញុំនឹងដើរចឹងជាមួយនឹងម្ដាយខ្ញុំកាលនឹង។

ក៖ចាំចឹងលោកយាយកាលនឹងដេលបានដើរលក់ជាមួយនឹងអ្នកម្ដាយរបស់លោកយាយកាលនឹងនៅខេត្តកំពុងស្ពឺនឹងចឹងកាលនឹងលោកយាយ?

ខ៖ចាំនឹងហើយខ្ញុំនឹងបានដើរលក់ជាមួយនឹងម្ដាយខ្ញុំនឹងនៅភូមិវត្តរត្ននានឹងចឹងទៅខ្ញុំកាលនឹង។

ក៖ហើយលោកយាយដែលបានចាំសាច់រឿងអីទៀតដែលលោកយាយកាលនឹងបានរស់នៅជាមួយនឹងម្ដាយឪពុកលោកយាយកាលនឹងដែលលោកយាយកាលនឹងក្រៅពីដើរលក់នំបាញ់ចុកកាលនឹងលោកយាយ?

ខ៖អត់ទរកាលនឹងម្ដាយខ្ញុំនឹងកាលនឹងគាត់នឹងមិនបានរកអីទៀតទរកាលនឹង។

ក៖ចាំចឹងកាលនឹងអ្នកម្ដាយរបស់កាលនឹងហើយគាត់នឹងបានរកស៊ីបន្តទៀតបានចិញ្ចឹមជាមួយនឹងលោកយាយហើយនឹងជាមួយនឹងប្អូនលោកយាយទៀតចឹងទៅណាលោកយាយចឹងកាលនឹងលោកយាយតាំងពីបានដាច់ពីជំនាន់លុននលនឹងមកហើយបានចូលមកអាពតនឹងលោកយាយបាននៅសល់តែបងប្អូននឹងតែពីនាក់នឹងទេលោកយាយ?

ខ៖ចាំនឹងហើយខ្ញុំនឹងបាននៅសល់តែខ្ញុំហើយនឹងប្អូនខ្ញុំនឹងតែម្នាក់នឹងហើយសល់ប៉ុន្មាននឹងបានស្លាប់បាត់អស់ហើយ។

ក៖ហើយសំរាប់លោកឪពុកហើយនឹងម្ដាយលោកយាយកាលនឹងពូកគាត់នឹងបានស្លាប់នៅជំនាន់សង្គ្រាមនឹងឬមួយក៏គាត់នឹងបានចប់សង្គ្រាមនឹងលោកយាយគាត់កាលនឹង?

ខ៖លោកឪពុកខ្ញុំនឹងគាត់កាលនឹងបានស្លាប់នៅជំនាន់សម័យសង្គ្រាមនឹងតែម្ដងកាលនឹងហើយចំណែកម៉ែខ្ញុំវិញនឹងគាត់កាលនឹងបានស្លាប់នឹងនៅជំនាន់អាពតនឹងកាលនឹងហើយកាលនឹងខ្ញុំនឹងមិនបាននបែកមកពីណាទេកាលនឹងហើយក្រោយមកខ្ញុំនឹងបានខំចាំមើលផ្លូវគាត់កាលនឹងថាគាត់នឹងបាននៅរស់ចឹងកាលនឹងហើយនឹងអីខ្ញុំនឹងបានបាត់បងប្អូនខ្ញុំហើយនឹងម្ដាយខ្ញុំនឹងមួយទៀតកាលនឹងទាំង៦នាក់នឹងកាលនឹងហើយកាលនឹងខ្ញុំនឹងបានខំចាំ

គាត់ចឹងកាលនឹងហើយខ្ញុំនឹងមិនបានឃើញគាត់នឹងមកចឹងកាលនឹងហើយខ្ញុំនឹងបានដឹងថាគាត់នឹងមានតែបានស្លាប់បាត់ហ៊ើកាលនឹងបើចឹងគាត់នឹងមកវិញហើយកាលនឹង។

កៈចឹងកាលនឹងដែលលោកយាយនឹងបានបាត់នឹងនឹងកាលនឹងជាបងៗកាលនឹងលោកយាយ?

ខៈអត់ទេកាលនឹងខ្ញុំនឹងបានបាត់បងខ្ញុំនឹងមួយហើយនឹងម្ដាយខ្ញុំនឹងដែលបានដែលបានបាត់នឹងប្អូនខ្ញុំនឹងកាលនឹងហើយនឹងម្ដាយខ្ញុំនឹងមួយទៀតចឹងកាលនឹងហើយចំណែកបងខ្ញុំនឹងដែលគាត់នឹងថាបានបាត់នឹងកាលនឹងបងខ្ញុំនឹងដែលគាត់នឹងបានធ្វើជាទាហានកាលនឹង។

កៈចាំចឹងកាលនឹងលោកយាយដេលបានបាត់នឹងគឺបងរបស់លោកយាយនឹង១ដែលបានប្រាប់ខ្ញុំគាត់នឹងបានធ្វើជាទាហានចឹងកាលនឹងហើយក្រោយមកលោកយាយនឹងបានបាត់ប្អូនលោកយាយដែលចឹងកាលនឹង?

ខៈអត់ទេកាលនឹងប្អូនខ្ញុំនឹងកាលនឹងវាមិនបានទាន់នឹងបានធ្វើអីទេកាលនឹងវាកាលនឹងស្ថិតតែនឹងបាន

ពឹងនៃ។

កៈចាំចឹងកាលនឹងប្អូនរបស់លោកយាយកាលនឹងគាត់ទាំងអស់គ្នានឹងបាននៅតូចចឹងកាលនឹងលោកយាយ?

ខៈកាលនឹងខ្ញុំនឹងមានប្អូនខ្ញុំនឹងបានធំដឹងក្ដីនឹងបាន១ហើយកាលនឹង។

កៈចឹងលោកយាយអាចប្រាបខ្ញុំបានទេថាលោកយាយអាចចាំឈ្មោះលោកយាយហើយនឹងលោកតាខាងឪពុកបានទេលោកយាយ?

ខៈតាខ្ញុំនឹងមានឈ្មោះតែកាលនឹងខ្ញុំនឹងបាចាំតែខាងឪពុកខ្ញុំកលនឹងអាកាលនឹងខ្ញុំនឹងបានចាំឈ្មោះខាងម្ដាយខ្ញុំទេកាលនឹងខាងឪពុកខ្ញុំនឹងមិនបានចាំទេតាខ្ញុំនឹងមានឈ្មោះតានួនហើយយាយខ្ញុំមានឈ្មោះយាយហៀងចឹងនឹងហើយជាឈ្មោះខាងម្ដាយខ្ញុំនឹងដែលជាអ្នកម្ដាយខ្ញុំហើយនឹងឪពុកខ្ញុំនឹងហើយតាយាយខ្ញុំនឹង។

កៈចាំចឹងកាលនឹងលោកយាយនឹងបានចាំតែម្ដាយហើយនឹងឪពុកខាងលោកយាយទេតែសំរាប់ខាងលោកឪពុកវិញមិនបានចាំទេចឹងលោកយាយ?

ខ៖ចាំកាលនឹងមូលហេតុដែលកាលនឹងខ្ញុំមិនបានចាំនឹងមកពីកាលនឹងកាលនឹងគាត់នឹងមានបងប្អូននឹងតែ២នាក់ទេណាកាលនឹងហើយគាត់នឹងបានកំព្រាតាមងពីគាត់នឹងនៅបាត់ចើងនឹងនៅក្រហាមចឹងកាលនឹងគាត់នឹងមិនបានដឹងម៉ែឪពុកទេកាលនឹង។

ក៖ចឹងឈ្មោះដែលលោកយាយនឹងបានប្រាប់ខ្ញុំមិចនឹងខាងអ្នកម្ដាយរបស់លោកយាយកាលនឹង?

ខ៖ចាំនឹងហើយដេលខ្ញុំនឹងបានប្រាប់នឹងគឺឈ្មោះខាងម្ដាយខ្ញុំទេ។

ក៖ចឹងលោកយាយដែលបានដែលចាំសាច់រឿងអីខ្លះពីពួកគាត់ទេកាលនឹង?

ខ៖ខាងសាច់រឿងជីតាខ្ញុំនឹងនៃ។

ក៖ចាំៗ

ក៖ជីតាខ្ញុំនឹងមានតែគាត់នឹងកាលនឹងគាត់នឹងបានក្រដែលនឹងកាលនឹងដល់តែកាលនឹងគាត់នឹងបានធ្វើតែស្រែដែលនឹងកាលនឹងគាត់នឹងនៅស្រុកគេហើយនឹងស្រុកេងកាលនឹងគាត់នឹងបានមានប្រពន្ធកាលនឹង២ហើយនឹង៣នាកើចឹងកាលនឹងយាយខ្ញុំនឹងបានស្លាប់នឹងកាលនឹងគាត់នឹងបានយកប្រពន្ធទៀតចឹងកាលនឹងហើយកាលនឹងគាត់នឹងចេះតែទៅមកផ្ទះនេះហើយនឹងប្រពន្ធនផះចឹងកាលនឹងតាខ្ញុំនឹងនឹងប្រវត្តិលោកតាខ្ញុំកាលនឹងណាហើយកាលនឹងគាតើមិនបានរកស៊ីអីទេកាលនឹង។

ក៖ចាំចឹងនឹងជាជីវប្រវត្តិលោកតាតរបស់លោកយាយហើយកាលនឹង?

ខ៖ចាំនឹងហើយដែលគាត់នឹងមិនបានជួយយាយខ្ញុំទេកាលនឹងតាខ្ញុំនឹងគាត់នឹងបានចូលចិត្តតែមានស្រីនឹងកាលនឹង។

ក៖ចាំចឹងតើក្រុមគ្រួសាររបស់លោកយាយកាលនឹងដែលបាននៅសល់នឹងហើ១ដូចជាលោកយាយបានរស់នៅនឹងហើយប្អូនលោកយាយកាលនឹងគាត់ក៏បានរស់នៅនឹងដែលតែខុសភូមិគ្នាកាលនឹងហើយចឹងកាលនឹងលោកយាយដែលបានរស់នៅភូមិដក់ពរនឹងហើយឃុំរល្វីសរនឹងហើយស្រុកសំរោងទងខេត្តសកំពុងស្ពឺនឹងចឹងលោកយាយហើយលោកយាយនឹងបានរស់នៅនឹងរបឆ្នាំតែម្ដងលោកយាយ?

ខ៖ខ្ញុំនឹងនែ៎។

ក៖ចាំលោកយាយហើយលោកយាយបានមករស់នៅនឹងតាំងពីអាពទមកម្លេះចងលោកយាយកាលនឹង?

ខ៖នឹងហើយកាលនឹងខ្ញុំនឹងបានមករស់នៅនឹងតាំងពីអាំពតមកម្លេះកាលនឹងខ្ញុំបានគិតទៅជិត៤០ឆ្នាំហើយខ្ញុំនឹងដែលបានមករស់នៅនឹង។

ក៖ចឹងលោកយាយបានមករស់នៅនឹង៣៥ឆ្នាំហើយនឹងលោកយាយចឹងកាលនឹងប្អូនលោកយាយដែលគាត់នឹងបានរស់នៅដល់រាល់ថ្ងៃនឹងជាប្អូនប្រុសឬក៏ជាស្រីដៃលោកយាយ?

ខ៖ប្អូនខ្ញុំនឹងប្រុស។

ក៖ចឹងគាត់នឹងបានរស់នៅណាដែលរាល់ថ្ងៃនឹងលោកយាយ?

ខ៖ប្អូនខ្ញុំនឹងវាបានរស់នៅជាប់ពពែកភ្នំ។

ក៖ពពែកភ្នំនឹងលោកយាយ?

ខ៖ចាំ

ក៖ចឹងលោកយាយដែលមានបងប្អូនណាដែលបានទៅរស់នៅអាមេរិចហើយនឹងមានរស់ថៃហើយនឹងវៀតណាមទេលោកយាយ?

ខ៖មាននឹងអត់ដែលនឹងមានគេទេកាលនឹង។

ក៖លោកយាយនេះខ្ញុំនឹងបានសម្ភាសន៍ជិវប្រវត្តិរបស់លោកយាយចឹងកាលនឹងតើលោកយាយបានរៀនការជាមយនឹងប្តីលោកយាយកាលនឹងឆ្នាំណាដេលទេលោកយាយហើយសំរាប់លោកយាយអាចប្រាប់គាត់នឹងអោយខ្ញុំនឹងបានដឹងថាតើលោកយាយបានការនឹងនៅឆ្នាំណាដែលលោកយាយ?

ខ៖ប្តីខ្ញុំនឹងគាត់នឹងមានឈ្មោះថាសូរធុន។

ក៖ហើយកាលនឹងលោកយាយនឹងបានរៀបកាលនឹងតាំងពីឆ្នាំណាមកចឹងកាលនឹង?

ខ៖ខ្ញុំនឹងបានការនឹងនៅណាទេកាលនឹង១៩៧២ដឹងកាលនឹថដែលខ្ញុំនឹងបានការនឹងជាមួយនឹងគាត់ណា។

កះចាំចឹងកាលនឹងលោកយាយដែលបានរៀបការនឹងណាហើយកាលនឹងលោកយាយនឹងបានរៀនកាលនឹងតាំងពីឆ្នាំ១៩៧២ចឹងកាលនឹងលោកយាយ?

ខះចាំចឹងកាលនឹងខ្ញុំនឹងបានរៀនការនឹងតាំងពីឆ្នាំ១៩៧២ចឹងកាលនឹងដែលខ្ញុំនឹងបានការចឹងកាលនឹង។

កះចាំចឹងកាលនឹងលោកយាយដេលបានចាំថាលោកយាយនឹងបានរៀនការនឹងតាំងពីខេណាហើយនៅថ្ងៃណាដែលលោកយាយ?

ខះកាលនឹងខ្ញុំនឹងមិនបានចាំទេកាលនឹងដែលខ្ញុំនឹងបានការកាលនឹង។

កះចឹងកាលនឹងលោកយាយមិនបានចាំទេកាលនឹងចឹងកាលនឹងលោកយាយដេលបានរៀបការនឹងតើកាលនឹងលោកយាយមានអ្នកណាដែលបានរៀបចំអោយលោកយាយកាលនឹងដែលបានការនឹងលោកយាយ?

ខះកាលនឹងខ្ញុំនឹងដែលបានការនឹងខ្ញុំនឹងបានរៀបចំដោយម៉ែខ្ញុំនឹងលោកឪពុកខ្ញុំកាលនឹង។

កះចឹងលោកយាយអាចប្រាប់ខ្ញុំបានទេថាកាលនឹងលោកយាយបានទទួលថ្លៃទឹកដោះកាលនឹងបានប៉ុន្មានដែលលោកយាយកាលនឹង?

ខះកាលនឹងយើងនឹងបានរៀបកាលនឹងខ្ញុំនឹងបានតែ៥០០០រៀលកាលនឹងដែលប្ដីខ្ញុំកាលនឹងគាត់បានអោយខ្ញុំចឹងកាលនឹង។

កះចាំចឹងកាលនឹងលោកយាយបានពីលោកតានឹងបានតែ៥០០០រៀលទេកាលនឹងលោកយាយ?

ខះចាំ!

កះអូចឹងកាលនឹងលោកយាយនឹងបានច្រើនណាស់លោកយាយកាលនឹងបើទិញមាសបាននឹងប៉ុន្មានដំឡឹងនោះ៥០០រៀលនឹង?

ខះ ទិញមាសនឹងខ្ញុំទិញបានតា៣ជីជាងទេ។

កះ អរបានតិចដោយសារអ្វីដែលលោកយាយ?

ខះ ព្រោះកាលនឹងខ្ញុំទុកលុយការ។

កៈ ចាំចឹងជាមូលហេតុអ្វីដែរស្វាមីលោកយាយបានជួបគ្នាជាមួយនឹងគាត់?

ខៈ ពេលនឹងគាត់ធ្វើជាទាហាន។

កៈ ចាំហើយកាលនឹងលោកយាយធ្វើអីគេដែលពេលនឹងលោកយាយបានជួបលោកតា?

ខៈ
ពេលនឹងខ្ញុំដើរទៅដូចយើងផ្លែគទុំចឹងថៅកែគេដើទិញដាក់នៅក្នុងរូងវែងៗចឹងណាស់យកទៅចាក់ចូលក្នុងរូងគេវែងៗចឹងទៅហើយខ្ញុំទៅបកគនឹងណាស់នៅក្នុងវែងនឹងធ្វើមួយថ្ងៃបាន២ ៣ កញ្ជេលចឹងណាស់កាលនឹងវាបានថ្លៃមួយកញ្ជេលនឹងបាន៥រៀល។

កៈ
ចាំចឹងលោកយាយអាចប្រាប់ខ្ញុំបានទេថាលោកយាយអាចសរសេរភាសាខ្មែរបានខ្លះៗទេលោកយាយ?

ខៈអត់សរសេរបានទេ។

កៈ ចាំចឹងលោកយាយអត់ដែលបានរៀនសោះលោកយាយ?

ខៈ ខ្ញុំរៀនដែលតែខ្ញុំអក្សរកម្មនឹង។

កៈ ចាំចឹងលោកយាយរៀនបានតែអក្សរកម្មទេធម្មតាទេលោកយាយ?

ខៈ ចាំតែបើអក្សរសរសេរមិនដឹងស្អីទេ។

កៈ ចាំចឹងតើលោកយាយអាចចេះនិយាយភាសាបរទេសបានខ្លះៗទេដូចជាថៃ វៀតណាមឡាវ អីទេលោកយាយ?

ខៈ អត់ទេខ្ញុំអត់ចេះទេ។

កៈ ចាំចឹងអង់គ្លេស បារាំង អីតើលោកយាយចេះទេ?

ខៈ អត់ទេខ្ញុំអត់ចេះទេ។

កៈ
អត់ទៀតចាំចឹងលោកយាយអាចប្រាប់ខ្ញុំបានទេថាពេលលោកយាយរៀនអក្សរកម្មនឹងតើលោកយាយរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែលលោកយាយ?

ខ៖ រៀនគេហៅអោយមករៀនពេលនឹងខ្ញុំអាយុច្រើដែលហើយនឹង។

ក៖ ចាំចឹងតើសាលារៀនដែលលោកយាយរៀននឹងតើមានឈ្មោះអ្វីដែលលោកយាយ?

ខ៖ ខ្ញុំរៀនតាមផ្ទះគេនឹងយើងរៀននៅក្រោមផ្ទះគេចឹងណាស់។

ក៖ អរចាំ?

ខ៖ មានរៀននៅសាលារៀនណា?

ក៖
ចាំចឹងតើលោកយាយអាប្រាប់ខ្ញុំបានទេថាតើលោកយាយធ្លាប់ទៅស៊ីឈ្នួលដក់ស្ទុងធ្វើស្រែអោយគេទេលោកយាយ?

ខ៖ ខ្ញុំធ្លាប់តារ។

ក៖ ចាំចុះកាលនឹងតើបានប្រាក់ក្នុងមួយថ្ងៃបានប៉ុន្មានដែលលោកយាយ?

ខ៖
កាលនឹងលុយថ្លៃខ្ញុំមិនដឹងបានមួយធ្លញប៉ុន្មានទេកាលនឹងខ្ញុំផ្លេចបាត់ហើយកាលជំនាន់នឹង។

ក៖
ចាំមិនអីទេលោកយាយចឹងពីបន្ទាប់ពីធ្វើស្រែដក់ស្ទុងអោយគេតើលោកយាយអាចធ្វើអ្វីទៀតទេលោកយាយ?

ខ៖ មានធ្វើអីមានតែពេលខ្ញុំធំនឹងខ្ញុំដើរបេកគអោយគេនឹង។

ក៖ អរចាំចឹងលោកយាយដើរស៊ីឈ្នួលបេកគអោយក្រុមហ៊ុនអោយគេទៅ?

ខ៖ ចាំ!

ក៖ ទិញសម្លឹគចឹងទៅលោកយាយ?

ខ៖ ចាំ!

កៈ

ចាំចឹងលោកយាយធ្វើការបកគអោយគេនឹងតើអស់រយះពេលប៉ុន្មានឆ្នាំហើយលោកយាយ?

ខៈ ខ្ញុំធ្វើការនឹងអស់ពេល៣ ៨ឆ្នាំហើយ។

កៈ ចាំលោកយាយធ្វើការនឹងអស់ពេល៣ ៨ឆ្នាំហើយលោកយាយ?

ខៈ ចាំ!

កៈ
ចាំចឹងតើលោកយាយអាចប្រាប់ខ្ញុំថាតើលោកយាយតាំងពីតូចរហូតមកដល់ធំតើលោកយាយមានផ្លាប់ផ្លាស់ប្តូរអ្វីខ្លះទេលោកយាយ?

ខៈ ផ្លាស់ប្តូមិចនាង។

កៈ
ការផ្លាស់ប្តូរនឹងដូចជាធ្លាប់ដក់ស្ទុងបកគអោយគេចឹងដុចជារកស៊ីអ្វីមួយអោយរីកចំរើនសំរាប់ក្រុមគ្រួសារណាស់តើលោកយាយមានធ្លាប់ធ្វើអ្វីផ្សេងពីនឹងទេលោកយាយ?

ខៈ អតើមានបានធ្វើអីទេកាលនឹងខ្ញុំធ្វើការតារបកគនឹងធ្វើស្រែនឹង។

កៈ
ចាំចឹងបកគហើយដល់ខែធ្វើស្រែចឹងទៅជាធម្មតាជាតំលាប់របស់លោកយាយទៅតាមរដូវការចឹងទៅចាំចឹងតើលោកយាយចូលចិត្តញ៉ាំម្ហូបអ្វីជាងគេដែលលោកយាយ?

ខៈ តារក្តោមត្រីសាច់ចឹងទៅ។

កៈ
ចាំបើលសិនចាល្បែងប្រជាប្រិយភាពដែលលោកយាយចូលចិត្តលេងតាំងពីតូចរហូតមកដល់ធំនឹងតើលោកយាយចូលចិត្តលេងមួយដែលដូចជា ចោលឈូង ទាញព្រាត់
លាក់កន្សែង ចោលអង្គុញ
អីតើលោកយាយចូលចិត្តលេងមួយណាជាងគេដែលលោកយាយ?

ខៈ ល្បែងទាំងអស់ខ្ញុំចូលចិត្តលេងទាំងអស់មីនាង។

កៈ ចាំចឹងដូចជាល្បែងប្រជាប្រិយនឹងទាំងអស់គឺលោកយាយចូលចិត្តលេងទាំងអស់?

ខៈ ចាំ!

កៈ ដូចជាគេលេងអីយើងចូលរួមលេងជាមួយគេដែល?

ខៈ ចាំ!លាក់កន្សែង ទាញ់ព្រាត់ ចោលឈូងអីចឹងទៅ។

កៈ
ចាំចឹងខ្ញុំសូមសួរលោកយាយបន្ថិចទៀតថាតើមានបទចម្រៀងមួយណាដែលលោកយាយចូលចិត្តស្តាប់តាំងពីតូចរហូតមកដល់ធំនឹងដែលលោកយាយស្តាប់ហើយដកជាប់នៅក្នុងអារម្មណ៍ចឹងណាស់តើលោកយាយចូលចិត្តមួយណាដែលលោកយាយ?

ខៈ ខ្ញុំចូលចិត្តបទពីសង្គមចាស់ណានាង។

កៈ ចាំដូចជារស់ស្រីសោភា លោកស្រីហ៊ុមស៊ីវ៉ន ដូចជាលោកតាសិនស៊ីសាមុតអី?

ខៈ ហ៊ុមស៊ីវ៉នឥឡូវអីខ្ញុំអត់ចូលចិត្តទេខ្ញុំចូលចិត្តប៉ែនរ៉ន ហិមស៊ីសាមុតអីចឹងទៅ។

កៈ
ចាំចឹងតើបទមួយណាដែលលោកយាយស្តាប់ទៅដែលដក់ជាប់នៅក្នុងអារម្មណ៍ជាងគេតើបទមួយណាដែលលោកយាយ?

ខៈ ខ្ញុំស្រលាញ់តារបទហ៊ុមស៊ីសាមុតអីនឹង។

កៈ
ចាំហើយតើលោកយាយអាចប្រាប់ខ្ញុំបានទេថាលោកយាយមានបងប្អូនណាដែលគេចេះលេងឧបគ្គភ្លេងដូចជា យីតា ស្គរ ចាប៉ី ទ្រ
អីចឹងណាស់តើលោកយាយមានអ្នកណាដែលគេចេះលេងទេដូចជាបងប្អូនរបស់លោកយាយណាស់?

ខៈ
មានតារកូនខ្ញុំនឹងវាទិញអាស្ទីទេវាទិញអារៀនចុចវាមិនសូវចេះទេតែវាចូលចិត្តខាងនឹង។

កៈ
ចាំចឹងតើលោកយាយអាចប្រាប់ខ្ញុំបានទេថាលក្ខណះផ្ទះរបស់លោកយាយមានលក្ខណះ

បែកណាដែរលោកយាយផ្ទះដែរលោកយាយរៀបការហើយមករស់នៅជាមួយប្តីប្រពន្ធលោកយាយនឹងនៅនឹងមែនលោកយាយ?

ខ៖
មិនមែនទេខ្ញុំរៀបការតាំងពីខាងលិចផ្សារស្ពឹម្លះតាំងពីឆ្នាំ៧២មកហើយនឹងផ្ទះនេះខ្ញុំមកនៅកាលជំនាន់ដាច់អាពតហើយនឹង។

ក៖ ចាំចឹងផ្ទះនឹងលោកយាយមករស់នៅតាំងពីជំនាន់ដាច់អាពតមក?

ខ៖ ចាំ!

ក៖ ចាំចឹងផ្ទះនឹងដូចជាមានលក្ខណះចឹងមកយូរហើយលោកយាយ?

ខ៖ យូរហើយ។

ក៖ ចាំដូចជាផ្ទះដំបូលសង្គស័យជញ្ជែងក្តាដុចជាទៀមជាប់ដីណាស់អ្នកមីង?

ខ៖ ពីមុនមកផ្ទះខ្ញុំផ្ទះស្លឹកទេដល់ពេលខ្ញុំលក់ដីលក់ស្រែទៅខ្ញុំធ្វើបានផ្ទះប៉ុននឹង។

ក៖ ចាំចឹងលោកយាយឈប់ធ្វើស្រែហើយ?

ខ៖ ចាំខ្ញុំឈប់ហើយខ្ញុំអស់ស្រែធ្វើហើយនឹង។

ក៖ ចាំបើលលោកយាយធ្វើក៏ធ្វើមិនបានទៀតដែលព្រោះលោកយាយចាស់ហើយ?

ខ៖ ចាំ!

ក៖
ចាំចឹងផ្ទះនឹងតើលោកយាយជយលគេឬមួយក៏លោកយាយធ្វើតារពីរនាក់ប្តីប្រពន្ធលោកយាយ?

ខ៖ ផ្ទះនឹងជួលគេធ្វើនាង។

ក៖
ចាំដូចជាសម្ភារះដែលលោកយាយជួលអោយគេធ្វើនឹងមានដូចជាក្តារដំបូលសង្គស័យដូចជាជញ្ជែងក្តារហើយទៀមជាប់ដីចឹងណាស់លោកយាយ?

ខ៖ ចាំ!

កៈ យើងអត់មានរនៀបទេយើងមានតារគ្រេលជាកន្លែងស្នាក់នៅម៉ង?

ខៈ ចា៎!

កៈ ចា៎ចឹងតើមានអ្នកជិតខាងណាដែលគេបង្រៀនធ្វើផ្ទះនឹងទេលោកយាយ?

ខៈ ខ្ញុំរកជាងគេមកធ្វើអោយណានាង។

កៈ ចា៎ចឹងអត់មានអ្នកជិតខាងណាគេមកជួយទេលោកយាយ?

ខៈ អត់មានទេខ្ញុំជួលជាងគេមកម៉ង។

កៈ
ចា៎ចឹងបើលសិនជាជំនាងដែលលោកយាយត្រូវរៀនណាស់បន្តពីក្រុមគ្រួសាដូចជាធ្វើសិប្បកម្ម ធ្វើវល ធ្វើការដេក្រម៉ាល
ដូចជាត្បាញសំពត់ដូចជាត្បាញកន្ទេលអីណាស់តើលោកយាយចេះធ្វើមួយណាដែលលោកយាយ?

ខៈ អត់ទេ។

កៈ ចឹងស្គត្នោចអីតើលោកយាយចេះកូរទេលោកយាយ?

ខៈ កាលមុនកាលជំនាន់អាពតប្ដីខ្ញុំគាត់ឡើងត្នោតដែលនឹង។

កៈ ចា៎ចឹងតើលោកយាយចេះកូរស្គរត្នោចទេលោកយាយ?

ខៈ ចា៎ខ្ញុំចេះ។

កៈ ចា៎លោកយាយចេះធ្វើនឹងលក្ខណៈចេះបន្តពីស្វាមីលោកយាយមក?

ខៈ ចា៎ប្ដីខ្ញុំគាត់ជាអ្នកបេះមកខ្ញុំជាអ្នករកអុសយកមកប្រកាត់ភ្លើងធ្វើស្គរត្នោតទៅ។

កៈ ចា៎កាលនឹងបានប្រាក់គួរសម្បមដែលលោកយាយ?

ខៈ ចា៎!

កៈ
ចាំចឹងតើបញ្ហាអ្វីខ្លះដែលលោកយាយថ្លាប់ឆ្លងកាត់ឧបសគ្គជាងគេតើលោកយាយធ្លាប់ឆ្លងកាត់អ្វីដែលខ្លះជាងដែលលោកយាយ?

ខៈ
ខ្ញុំឆ្លងកាត់អាជីវភាពក្រខ្សត់លក់នំបញ្ចុកនឹងខ្ញុំក្រជាទីបំផុតយើងធ្វើស្រែម៉ងបានយើងខ្ចីគេស៊ីបន្ទាក់គេស៊ីចឹងទៅដល់ពេលបានមកយកសងគេអស់ដល់ពេលចឹងស្អែតទៀតចឹងណាស់។

កៈ ចាំចឹងតើមានពេលណាដែលលោកយាយសប្បាយចិត្តជាងគេដែលលោកយាយ?

ខៈ
ខ្ញុំអត់មានពេលណាដែលខ្ញុំសប្បាយចិត្តទេនៅក្នុងមួយជីវិត្តខ្ញុំនេះខ្ញុំពិបាកខ្ញុំក្រមួយចប់។

កៈ ចាំតាំងពីងតូចដល់ធំ?

ខៈ ចាំខ្ញុំអត់មានកន្លែងណាដែលខ្ញុំសប្បាយចិត្តទេ។

កុៈ
ចាំចឹងតាំងពីតូចរហូតមកដល់ធំនឹងតើលោកយាយមានបំណងប្រាថ្នាថាចង់ខ្លាចជាអ្វីទេ?

ខៈ តាំងពីតូចមកខ្ញុំនឹកពងប្រាថ្នាថាពេលនឹងខ្ញុំប្រលងចម្រៀងពេលនងខ្ញុំចង់ធ្វើណាស់។

កៈ លោកយាយចង់ធ្វើជាដារា?

ខៈ ចាំខ្ញុំធ្លាប់ទៅប្រលងចម្រៀងម្តងបទដុរីចាលុងខ្ញុំច្រៀងជាប់ណាស់។

កៈ អរចាំ!

ខៈ ប្អូនខ្ញុំនៅពេទ្យភ្នំវាជួញខ្ញុំទៅខូសស្នាការ។

កៈ ចាំពេលជាប់?

ខៈ
ពេលនឹងច្រៀងជាប់ដល់ពេលថ្ងៃក្រោយខ្ញុំទៅមើលគេចេញរស្មោដល់ហើយគេចេញទៀតដល់ហើយខ្ញុំធ្លាក់គេអោយខ្ញុំច្រៀងសាក់ទៀតដល់ហើយគេអោយខ្ញុំទៅច្រៀងសាក់ទៀតក៏

ធ្លាក់ទៀតយើងអត់មានប្រិចប្រាងថាយើងជាប់ហើយយើងអត់មានថាខ្លាចធ្លាក់ទៀតទេខ្ញុំមួយជីវិតខ្ញុំពងចឹង។

ក៖ អរចាំលោកយាយចង់ធ្វើជាដារាចង់ខ្លាចទៅជាអ្នកចំរៀងអីចឹងទៅ?

ខ៖ ចាំ!

ក៖
ចាំចឹងតើលោកយាយមានអ្វីដែលត្រូវផ្ដែផ្ដៅទៅកូនចៅជំនាន់ក្រោយរបស់លោកយាយទេ?

ខ៖ កូនចៅខ្ញុំនឹង។

ក៖ ចាំ!

ខ៖
ខ្ញុំមានតាផ្ដែផ្ដៅទៅអោយកូនចៅទាំងអស់គ្នាអោយខ្ញុំរកស៊ីខ្លួនឯងខ្ញុំអោយមានការលំបាកណាស់នាង។

ក៖ ចាំ!

ខ៖
ខ្ញុំចេះតែនិយាយជេស្ដីអោយវាខំប្រឹងរកស៊ីចិញ្ចឹមខ្លួនឯងចឹងទៅកុំអោយមានការលំបាក។

ក៖
ចាំចឹងតើលោកយាយអាចផ្ដែផ្ដៅទៅអោយកូនចៅជំនាន់ក្រោយអោយពួកគាត់ខិតខំប្រឹងប្រែងរៀនសូត្រដើម្បីមានមុខរបរខ្លួនឯងចឹងណាស់លោកយាយ?

ខ៖ នឹងហើយខ្ញុំមានតារពាក្យផ្ដែផ្ដៅទៅអោយចឹងទេអោយខំប្រឹងប្រែងរកស៊ីចិញ្ចឹមកូន។

ក៖ ចាំនឹងអោយកូនខំប្រឹងរៀនសូត្រចឹងទៅ?

ខ៖ ចាំ!អោយកូនចៅខំប្រឹងរៀនសូត្រ។

ក៖
ចាំ!ហើយបើការជៀសវាងតើលោកយាយគួរអោយពួកគាត់ជៀសរៀងអ្វីខ្លះដែលលោកយាយ?

ខ៖ អោយកូនអោយចៅជៀសវៀងពីរឿងចោលពីរឿងថ្នាំញៀញអីនឹងណានាង។

ក៖ ចាំអោយពួកគាត់ជៀសវៀងទៅលោកយាយណាស់?

ខ៖ ចាំ!

ក៖ ចាំចឹងតើលោកយាយមានអ្វីទៀតទេលោកយាយ?

ខ៖ ចាំខ្ញុំអត់មានអ្វីទៀតទេ។

ក៖
ចាំចឹងខ្ញុំសូមអរគុណលោកយាយដែលលោកយាយចំណាយពេលវេលាដល់មានដម្លៃអោយខ្ញុំធ្វើការសំម្ភាសន៍អំពីខ្សែជីវិត្តរបស់លោកយាយផងដែលចឹងខ្ញុំសូមអរគុណលោកយាយម្តងទៀតផងដែលសូមអោយលោកយាយមានសុខភាពល្អរកស៊ីមានបានផងដែលចាំអរគុណលោកយាយ។